ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីថ្លែងការណ៍
# របស់អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជំទាស់យ៉ាងខ្លាំងក្លាចំពោះការប្រកាសកាលពីថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៨ ដោយក្រសួងរតនាគាររបស់អាមេរិក ចោទប្រកាន់ ឯកឧត្តម នាយឧត្តមសេនីយ ហ៊ីង ប៊ុនហៀង ពីការរំលោភសិទ្ធិមនុស្ស។

២. ខ្លឹមសារនៃការប្រកាសនេះ ធ្វើអោយមានការស្រងាកចិត្តយ៉ាងខ្លាំង នៅពេលដែលបុគ្គលសាធារណៈរបស់ប្រទេសមួយ ត្រូវបានក្លាយទៅជាកម្មវត្ថុនៃវិធានការទណ្ឌកម្មរបស់ប្រទេសដទៃផ្សេងទៀត ដោយផ្អែកលើការចោទប្រកាន់ដោយគ្មានមូលដ្ឋាន និងគ្មានការគោរពទាល់តែសោះចំពោះភាពឯករាជ្យនៃច្បាប់ និងយុត្តិធម៌របស់ប្រទេសមួយ។ នេះគឺជាការបំពានដោយគឃ្លើនលើគោលការណ៍អន្តរជាតិស្តីពីគោល-ការណ៍ស្មើភាពនៃអធិបតេយ្យ និងគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ។

៣. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រានចោលយ៉ាងដាច់អហង្ការ ចំពោះការចោទប្រកាន់កងកម្លាំងប្រដាប់អាវុធរបស់កម្ពុជា ពីបទចូលរួមពាក់ព័ន្ធការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មលើប្រជាជនខ្លួនឯង។ ផ្ទុយទៅវិញ នរណាក៏ដឹងដែរថា ឯកឧត្តម នាយឧត្តមសេនីយ ហ៊ីង ប៊ុនហៀង និងបញ្ជាការដ្ឋានអង្គរក្ស បានចូលរួមចំណែកយ៉ាងធំធេងក្នុងការរក្សាសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សង្គម ជាពិសេសការការពារឯករាជ្យ និងបូរណភាពដែនដី ប្រឆាំងនឹងការឈ្លានពានរបស់បរទេស។

៤. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចាត់ទុកចំណាត់ការជាឯកតោភាគីរបស់អាមេរិក ជាទង្វើដែលមានបង្កប់របៀបវារៈនយោបាយ និងមានការវិនិច្ឆ័យលំអៀង ផ្ទុយនឹងកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសទាំងពីរក្នុងការរក្សាទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីយូរអង្វែង ឈរលើការគោរពគ្នាទៅវិញទៅមក ផលប្រយោជន៍រួម និងការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងផងគ្នា។ សហរដ្ឋអាមេរិកហាក់បីដូចជាមើលមិនឃើញនូវគោលនយោបាយអតីតកាលរបស់ខ្លួន ក្នុងការផ្លាស់ប្តូររបបតាមបែបមិនប្រជា-ធិបតេយ្យ ដែលបាននាំមកនូវការបំផ្លិចបំផ្លាញប្រជាជននិងប្រទេសជាតិដ៏តូចមួយនេះនៅអាស៊ីអាគ្នេយ៍ ហើយកាកសំណល់សង្គ្រាមនេះស្ថិតនៅរាយប៉ាយទូទាំងប្រទេស និងនៅបន្តជាបញ្ហាប្រឈមយ៉ាងធំធេងចំពោះការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់កម្ពុជា។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

៥. រឿងរ៉ាវដ៏អយុត្តិធម៌ជាក់ស្តែងបំផុតនោះគឺ នៅពេលដែលអតីតរដ្ឋបាលអាមេរិកបានដឹកនាំបង្កើតសម្ព័ន្ធមិត្តគាំទ្ររបបខ្មែរក្រហម ដែលគ្រប់គ្រងប្រទេសដោយការរំលោភសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យយ៉ាងពេញទំហឹង ឱ្យកាន់កាប់អាសនៈកម្ពុជានៅអង្គការសហប្រជាជាតិ និងដាក់ទណ្ឌកម្មដ៏អយុត្តិធម៌អស់រយៈពេល១២ឆ្នាំ ប្រឆាំងនឹងប្រជាជាតិមួយដែលទទួលរងការបំផ្លិចបំផ្លាញដោយសារការទម្លាក់គ្រាប់បែករបស់អាមេរិកច្រើនជាងពីរលានតោន។

៦. ការកំណត់ពេលចេញសេចក្តីថ្លែងការណ៍ក្នុងពេលនេះអាចចាត់ទុកថាជាយុទ្ធនាការដែលមានការសម្របសម្រួលគ្នាសំដៅវាយប្រហារជាបន្តបន្ទាប់មកលើកិត្យានុភាពរបស់រាជរដ្ឋាភិបាលកម្ពុជា នៅមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅខែកក្កដាខាងមុខ។ យើងសូមធ្វើការកត់សម្គាល់ដោយងឿងឆ្ងល់ថារដ្ឋាភិបាលសហរដ្ឋអាមេរិកមិនដែលថ្កោលទោសក្រុមប្រឆាំងមួយចំនួនក្នុងប្រទេសម្ពុជា ដែលធ្វើសកម្មភាពនយោបាយដោយការជេរប្រមាថ ការប្រកាន់ពូជសាសន៍ បង្កការស្អប់ខ្ពើមនៅក្នុងសង្គម និងការបរិហារកេរ្តិ៍។ ទង្វើទាំងអស់នេះសុទ្ធតែត្រូវបានថ្កោលទោសយ៉ាងខ្លាំងនៅក្នុងប្រទេសប្រជាធិបតេយ្យនានា។

៧. ទោះជាយ៉ាងណាក៏ដោយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមអះអាងជាថ្មីម្តងទៀតនូវការប្តេជ្ញាចិត្តឥតងាករេរបស់កម្ពុជាក្នុងការបន្តអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការអនុវត្តនីតិរដ្ឋ និងការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅថ្ងៃទី ២៩ ខែកក្កដាឆ្នាំ ២០១៨ ដោយសេរី តម្លាភាព និងមានរបៀបរៀបរយ។

ថ្ងៃ ពុធ ១កើត ខែបឋមាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨